00295983

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 06 / APR / 2009
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Fuy

ការ/N: D130/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 06 / APR / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Fuy

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**
**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 002/19-09-2007-ECCC-OCIJ**

# ដីកាសម្រេចស្តីពីការស្នើសុំបន្ថែមចំនួនទំព័រ

# Order on Request for Extension of Page Limit

# Ordonnance sur demande d'extension de nombre de pages

យើង **យូ ប៊ុនឡេង** និង **Marcel LEMONDE** សហចៅក្រមស៊ើបអង្កេតនៃអង្គ ជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.")

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក.")

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **អៀង ធីរិទ្ធ** និង **ជនផ្សេងទៀត** ទាក់ទងនឹងបទចោទប្រកាន់ **អំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពី អ.វ.ត.ក.

បានឃើញវិធាន ៣៩(៦) និង ៥៥(៥) នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក. ("វិធានផ្ទៃក្នុង")



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * ECCC * CETC

បានឃើញមាត្រា ៥.១ និង ៥.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក. ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៨ ("សេចក្តីណែនាំអនុវត្ត")

## ការរំលឹកឡើងវិញអំពីនីតិវិធី

១. នាថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩ ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ បានដាក់សំណើសុំច្រានចោលភស្តុតាង ដែលបានមកដោយការធ្វើទារុណកម្ម (D130)។

២. នាថ្ងៃទី ០៣ ខែ មីនា ២០០៩ សហព្រះរាជអាជ្ញាបានដាក់សំណើសុំបន្ថែមចំនួនទំព័រ ដើម្បីដាក់ចម្លើយតបទៅនឹងសំណើរបស់ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ ស្នើសុំសុំច្រានចោលភស្តុតាង ដែលបានមកដោយការធ្វើទារុណកម្ម (D130/1)។

៣. នាថ្ងៃទី ០៦ ខែ មីនា ២០០៩ ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ បានឆ្លើយតបជំទាស់ទៅនឹងសំណើសុំបន្ថែមចំនួនទំព័ររបស់សហព្រះរាជអាជ្ញា (D130/2)។

## ច្បាប់ដែលត្រូវអនុវត្ត

៤. អនុលោមតាមវិធាន ៣៩(៦) នៃវិធានផ្ទៃក្នុង មាត្រា ៥.១ និង ៥.៤ នៃសេក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារបានចែងថា ឯកសារដាក់នៅសហចៅក្រមស៊ើបអង្កេត មិនត្រូវលើសពី ១៥ ទំព័រជាភាសាអង់គ្លេស ឬបារាំង ឬ ៣០ទំព័រជាភាសាខ្មែរ លើកលែងតែ តាមការស្នើសុំរបស់ភាគីចូលរួម សហចៅក្រមស៊ើបអង្កេតអាចអនុញ្ញាតឲ្យមានការបន្ថែមចំនួនសន្លឹកឯកសារ នៅក្នុងកាលៈទេសៈពិសេសណាមួយ។

00295985



## <u>សំអាងហេតុនៃសេចក្តីសម្រេច</u>

៥. នៅក្នុងសំណើសុំបន្ថែមចំនួនទំព័រនោះ សហព្រះរាជអាជ្ញាបានបង្ហាញពីចេតនារបស់ខ្លួនក្នុងការដាក់សារណាតបនៅថ្ងៃ ឬមុនថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩ បើគិតទៅ គឺមានមានរយៈពេលជាងពីរខែកន្លះ បន្ទាប់ពីការដាក់សំណើសុំ ដែលធ្វើឡើងដោយក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ (“ក្រុមមេធាវីការពារក្តី”)។ សហព្រះរាជអាជ្ញាបានបញ្ជាក់បន្ថែមទៀតថា ដោយសារបញ្ហានេះជាបញ្ហាសំខាន់ ការបន្ថែមចំនួនទំព័រឱ្យបានដល់សាមសិបទំព័រ ក្នុងអត្ថបទជាភាសាអង់គ្លេស ជារឿងចាំបាច់ ដើម្បីឱ្យគូភាគីអាចធ្វើសារណាបានគ្រប់គ្រាន់ជូនសហចៅក្រមស៊ើបអង្កេត។ ផ្អែកលើយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិទាក់ទងនឹងបញ្ហានេះ សហព្រះរាជអាជ្ញាបានលើកឡើងអំពី “កាលៈទេសៈពិសេស” ដោយសម្អាងថាបញ្ហានេះមានលក្ខណៈស្មុគ្រស្មាញ និងដែលតម្រូវឱ្យមានការវិភាគលើបញ្ញត្តិច្បាប់ទាំងឡាយ ព្រមទាំងយុត្តិសាស្ត្រចាប់តាំងពីសង្គ្រាមលោកលើកទីពីរមកម្ល៉េះ។ ដូចគ្នានេះ ក៏ត្រូវសិក្សាវិភាគផងដែរលើទិដ្ឋភាពច្បាប់កម្ពុជា និងអត្ថបទវិភាគរបស់អ្នកស្រាវជ្រាវនានា ទាក់ទងនឹងបញ្ហាមួយនេះ (កថាខណ្ឌ ២ និង ៣)។

៦. ក្រុមមេធាវីការពារក្តីជំទាស់តបថា មិនមានកាលៈទេសៈពិសេសណាមួយនោះទេ នៅក្នុងរឿងនេះ ដោយហេតុថា ភាពស្មុគ្រស្មាញ ដែលបានលើកឡើងមកនេះ មិនអាចជាហេតុផលមួយនៃការ មិនគោរពការកំណត់ចំនួនទំព័រនោះទេ (កថាខណ្ឌ ៧)។ ក្រុមមេធាវីការពារក្តីបានបញ្ជាក់ថា យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា មិនអាចជាមូលដ្ឋានគាំទ្រដល់សំណើសុំបន្ថែមចំនួនទំព័រនោះទេ ដោយចាត់ទុកថា យុត្តិសាស្ត្រដែលបានលើកឡើង ត្រូវបានសម្រេចឡើងក្នុងកាលៈទេសៈមួយខុសពីស្ថានភាពនៃបញ្ហានេះ ជាពិសេស តាមដែលយើងឃើញ ការអនុញ្ញាតឱ្យមានការបន្ថែមចំនួនទំព័រនៅក្នុងយុត្តិសាស្ត្រទាំងនោះត្រូវបានផ្តល់ឱ្យតែអ្នក ដែលធ្វើសារណាដំបូងតែប៉ុណ្ណោះ គឺមិនមែនផ្តល់ឱ្យដល់អ្នក ដែលត្រូវធ្វើចម្លើយតបនោះទេ (កថាខណ្ឌ ៩-១៦)។ ក្រុមមេធាវីការពារក្តីបានលើកឡើងបន្ថែមទៀតថា ប្រសិនបើការកំណត់ចំនួនទំព័រត្រូវបានគោរពអនុវត្ត នោះសហព្រះរាជអាជ្ញានឹងមិនត្រូវការពេលវេលាយូរបែបនេះ ក្នុងការធ្វើចម្លើយតបនោះទេ (កថាខណ្ឌ ១៨)។ ជាចុងក្រោយ ក្រុមមេធាវីការពារក្តីបានបញ្ជាក់បន្ថែមថា និយាមមូលដ្ឋានពិត



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

ប្រាកដក្នុងការ ដែលកំណត់ឱ្យមានការបន្ថែមចំនួនទំព័រ គឺអត្ថិភាពនៃកាលៈទេសៈពិសេស គឺមិនមែនជាបញ្ហា ដែលថាតើការបន្ថែមនោះអាចប៉ះពាល់ដល់សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌នោះទេ (កថាខណ្ឌ ១៩-២១)។

## ហេតុផលនៃសេចក្តីសម្រេច

<u>និយាមជាមូលដ្ឋាន ដែលត្រូវអនុវត្ត</u>

៧. ដូចដែលក្រុមមេធាវីការពារក្តីបានលើកឡើងដោយត្រឹមត្រូវរួចមកហើយ (កថាខណ្ឌ ១៨) ដោយគិតទៅលើសារជាតិនៃដំណើរការនៃកិច្ចស៊ើបសួរ រាល់សារណា ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា ទាក់ទងនឹងបញ្ហានៃភស្តុតាង ដែលទទួលបានដោយការធ្វើទារុណកម្ម នឹងមិនមានការកំហិតពេលវេលាចំពោះការធ្វើ "ចម្លើយតប" នៅចំពោះមុខអង្គតុលាការផ្សេងៗនៃ អ.វ.ត.ក. នោះទេ។ មានលក្ខខណ្ឌតែមួយគត់ គឺការកំណត់ចំនួន ១៥ ទំព័រ (ក្នុងអត្ថបទជាភាសាអង់គ្លេស) ចំពោះទំហំឯកសារ ដែលត្រូវដាក់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ផ្អែកតាមមាត្រា ៥.១ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។

៨. ក្នុងន័យនេះ យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ ដែលបានលើកឡើងទាក់ទងនឹងការដាក់ឯកសារដំបូង និងការធ្វើចម្លើយតប ដូចដែលបានវិភាគវែកញែកដោយភាគីទាំងពីរនៅក្នុងអត្ថបទរបស់ខ្លួន មិនអាចត្រូវបានអនុវត្តនៅក្នុងបញ្ហានេះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏យុត្តិសាស្ត្រទាំងនោះអាចនឹងប្រើប្រាស់បាន ទាក់ទងនឹងលក្ខណៈវិនិច្ឆ័យដើម្បីកំណត់អំពីអត្ថិភាពនៃ "កាលៈទេសៈពិសេស" នៅក្នុងរឿងក្តីជាក់ស្តែងនីមួយៗ។

៩. ជាងនេះទៅទៀត យុត្តិសាស្ត្រ ដែលលើកឡើងដោយសហព្រះរាជអាជ្ញាបានបង្ហាញអំពីការព្រួយបារម្ភជាទូទៅមួយរបស់តុលាការអន្តរជាតិ ក្នុងការធានាឱ្យមានសមភាពនៃគូភាគីក្នុងការការពារក្តី[1]

---

[1] សូមមើលជាឧទាហរណ៍: ICTY ព្រះអាជ្ញា ទល់នឹង Seselj អង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេចចំពោះសំណើសុំរបស់ព្រះរាជអាជ្ញាក្នុងការបន្ថែមចំនួនទំព័រឱ្យលើសពី ១០ ថ្ងៃទី ៤ ខែកុម្ភៈ ២០០៤ ទំព័រ ២។ និង SCSL ព្រះរាជអាជ្ញា





CO-INVESTIGATING JUDGES * ECCC * CETC * CO-JUGES D'INSTRUCTION

00295987

ឯកសារ: D130/3

និងជៀសវាងភាពយឺតយ៉ាវ ដែលមិនចាំបាច់[2] តាមរយៈការអនុវត្តន៍ដោយសមរម្យនៃវិធាន ដែលពាក់ព័ន្ធនឹងការកំណត់ចំនួនទំព័រ។ ជាចុងក្រោយ សហព្រះរាជអាជ្ញា បានបង្ហាញអំពីគោលជំហររបស់ខ្លួនយ៉ាងច្បាស់លាស់ថា ខ្លួនចង់ឱ្យសារណារបស់ខ្លួន ជាចម្លើយតបទៅនឹងសំណើសុំរបស់ក្រុមមេធាវីការពារក្តី។

១០. ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា ក្រៅពីការវាយតម្លៃអំពីអត្ថិភាពនៃកាលៈទេសៈពិសេស ពួកគេក៏ត្រូវគិតគូរផងដែរ អំពីតម្រូវការក្នុងការធានាអំពីសមភាពនៃគូរភាគីក្នុងការការពារក្តី និងការជៀសវាងភាពយឺយ៉ាវ ដែលមិនចាំបាច់។

<u>កាលៈទេសៈពិសេស</u>

១១. នៅក្នុងបញ្ហានេះ បញ្ហានៃការប្រើប្រាស់ដោយត្រឹមត្រូវនៃភស្តុតាង ដែលទទួលបានដោយការធ្វើទារុណកម្ម គឺវាមានលក្ខណៈច្បាស់លាស់ណាស់ បើគិតអំពីចំនួនដ៏ច្រើននៃឯកសារ ដែលទទួលបានពីមន្ទីរ ស-២១ ហើយដែលត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង។

១២. ទោះបីជាយ៉ាងណាក៏ដោយ ដោយហេតុថាសហចៅក្រមស៊ើបអង្កេតមានសមត្ថកិច្ច ផ្អែកតាមវិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង ក្នុងការដំណើរការកិច្ចស៊ើបសួរដោយខ្លួនឯង ដូច្នេះវាមិនមែនជាការចាំបាច់ទេ ក្នុងរឿងដែលថា សារណារបស់ភាគីត្រូវធ្វើការវិភាគយ៉ាងល្អិតល្អន់លើគ្រប់ទិដ្ឋភាពនៃបញ្ហានោះទេ[3]។

---

ទល់នឹង Brima Kamara និង Kanu សេចក្តីសម្រេចលើសំណើសុំបន្ទាន់ឱ្យមានការបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្តឹងឧទ្ធរណ៍ ថ្ងៃទី ២៤ សីហា ២០០៧ កថាខណ្ឌ ៧។

[2] សូមមើលជាឧទាហរណ៍ ICTY រដ្ឋអាជ្ញា ទល់នឹង Kordic និង Cerkez អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សេចក្តីសម្រេចឱ្យអ្នកធ្វើបណ្តឹងឧទ្ធរណ៍តាក់តែងសារណាលើសពីការកំណត់ដោយសេចក្តីណែនាំអនុវត្ត ថ្ងៃទី ២៩ សីហា ២០០១ កថាខណ្ឌ ៦។

[3] ចំពោះហេតុផលស្រដៀងគ្នានេះ ដែលអនុវត្តនៅចំពោះមុខ ICTY ទាក់ទងនឹងការកំណត់ចំនួនទំព័ររបស់សារណាមុខអង្គសេចក្តី សូមមើល: ICTY រដ្ឋអាជ្ញា ទល់នឹង Stanisisc និង Simatovic អង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេចទាក់ទងនឹងសំណើសុំរបស់ក្រុមមេធាវីការពារក្តីសុំបន្ថែមចំនួនទំព័រសម្រាប់សារណាមុនអង្គសេចក្តី ថ្ងៃទី ០៦ ធ្នូ ២០០៤។



C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

00295988

ឯកសារ/N: D 130/3

១៣. បន្ថែមលើសពីនេះទៀត បញ្ហានេះមិនធ្លាប់ត្រូវបានលើកឡើងនៅចំពោះមុខអង្គតុលាការផ្សេងទៀតនៃ អ.វ.ត.ក. ទេ ហើយក៏មិនធ្លាប់ជាកម្មវត្ថុនៃសារណារបស់អ្នក ដែលមិនមែនជាភាគីដែរ (Amicus curiae) ដែរ។ ជាក់ស្តែង គឺតាមរយៈ សារណានៃអ្នកដែលមិនមែនជាភាគីនេះហើយ ដែលនាំឱ្យសហចៅក្រមស៊ើបអង្កេតយល់ស្របលើការស្នើសុំបន្ថែមចំនួនទំព័រ ទាក់ទងនឹងបញ្ហាសហឧក្រិដ្ឋកម្មរួម (JCE)។ អាស្រ័យហេតុនេះ ក្នុងករណីនេះ យើងគិតថា លក្ខណៈពិសេស ដែលជាកត្តានាំឱ្យមានការបន្ថែមចំនួនទំព័រ នៅពុំទាន់មានលក្ខណៈគ្រប់គ្រាន់សមហេតុផលនៅឡើយទេ។

<u>ភាពយឺតយ៉ាវ ដែលមិនចាំបាច់</u>

១៤. ទោះបីជាវាមានលក្ខណៈផ្ទុយទៅនឹងទម្លាប់ករណ៍ ដែលលើកឡើងដោយក្រុមមេធាវីការពារក្តី ក៏ដោយ (កថាខណ្ឌ ១៩) សហចៅក្រមស៊ើបអង្កេតគិតថា រយៈពេលយូរ ដែលអូសបន្លាយរបស់សហព្រះរាជអាជ្ញា គួរតែជាផ្តល់លទ្ធភាពឱ្យពួកគេក្នុងការធ្វើសារណាមួយ ដែលមានលក្ខណៈ សង្ខេបខ្លី និងច្បាស់លាស់។ ជាក់ស្តែងដូចដែល Hunt J. បានបញ្ជាក់នៅក្នុងយុត្តិសាស្ត្រ ដែលលើកឡើងដោយសហព្រះរាជអាជ្ញា៖

*វាគឺជាការទទួលស្គាល់ទូទៅ ដោយអ្នកដែលមានបទពិសោធន៍ក្នុងការតាក់តែងសារណាជាលាយលក្ខណ៍អក្សរ ក្នុងរឿងដែលថា ត្រូវចំណាយពេលយូរដើម្បីសរសេរតាក់តែងឱ្យបានខ្លីច្បាស់លាស់ ជាងការណ៍ ដែលធ្វើវាដោយផ្ទាល់មាត់...*[4]

១៥. ចំពោះករណីនេះ សហចៅក្រមស៊ើបអង្កេតមិនចាត់ទុកថា ការរង់ចាំការដាក់សារណារបស់សហព្រះរាជអាជ្ញា នឹងបង្កើតឱ្យមានការយឺតយ៉ាវ ដោយឥតចាំបាច់នោះទេ បើគិតអំពីស្ថានភាពបច្ចុប្បន្ននៃដំណើរការនៃកិច្ចស៊ើបសួរ។ ប៉ុន្តែផ្ទុយទៅវិញ ការអូសបន្លាយនៃរយៈពេលនេះ អាចធ្វើឱ្យលទ្ធភាពនៃសំណើសុំបន្ថែមចំនួនទំព័រ កាន់តែខ្សោយទៅៗ។

---

[4] សូមមើលឧទាហរណ៍ ICTY រដ្ឋអាជ្ញា ទល់នឹង Kordic និង Cerkez អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សេចក្តីសម្រេចឱ្យអ្នកធ្វើបណ្តឹងឧទ្ធរណ៍តាក់តែងសារណាលើសពីការកំណត់ដោយសេចក្តីណែនាំអនុវត្ត ថ្ងៃទី ២៩ សីហា ២០០១ កថាខណ្ឌ 4។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION E.C.C.C * C.E.T.C

00295989

ការ/ការ: D130/3

<u>សមភាពនៃគូភាគីក្នុងការការពារក្តី</u>

១៦. សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ឃើញថា ក្រុមមេធាវីការពារក្តីបានបំពេញការងាររបស់ខ្លួន ដោយមិនបានស្នើសុំឱ្យមានការបន្ថែមចំនួនទំព័រនោះទេ ហើយថែមទាំងបានបដិសេធជំទាស់ទៅនឹងសំណើសុំបែបនេះទៀតផង។

១៧. ប្រសិនបើសំណើសុំរបស់សហព្រះរាជអាជ្ញាបានទទួលការយល់ព្រម នោះហាក់បីដូចជាអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាធ្វើនូវចម្លើយតបមួយ ដែលមានទំហំធំជាងពីរដង បើប្រៀបធៀបទៅនឹងសំណើសុំដំបូង នេះគឺជាបញ្ហាពិតប្រាកដជាក់ស្តែងមួយ ដែលប៉ះពាល់ដល់សមភាពនៃគូភាគីក្នុងការការពារក្តី។

## ហេតុដូច្នេះសម្រេច

- **កត់សម្គាល់** លើសេចក្តីបញ្ជាក់របស់សហព្រះរាជអាជ្ញា ដែលក្នុងនោះសហព្រះរាជអាជ្ញាមានបំណងនឹងដាក់សារណាឆ្លើយតប មុន ឬនៅថ្ងៃទី ៣០ ខែ មេសា ២០០៨។ និង
- **បដិសេធ** សំណើសុំបន្ថែមចំនួនទំព័រនេះ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៨

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**
**Co-juges d'instruction**

MARCEL Lemonde

យូ ប៊ុនឡេង



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.